ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២៥/១៧ - អេ អិម ៣ ខេមបូឌា ហ្គាមេន ខូ អិលធីឌី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៧

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ុក រី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៣៨០ ៥១១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក យន លីយ៉ុង រដ្ឋបាល

២- កញ្ញា ង៉ោន មិនា គណនេយ្យ

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ខូ អិលធីឌី**

- **សហជីពយុវជនខ្មែរនៃក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១១ ៥៣៣ ១៤៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ម៉ៃ វឌ្ឍនា | អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ |
| ២- លោកស្រី យិន កញ្ញា | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ៣- លោក សំ បូរ៉ា | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ៤- លោក ប៊ូ ខេមរា | ប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន |
| ៥- លោក ផុន ហុងលី | អនុប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនធ្វើកិច្ចសន្យាការងារមានកំណត់ថិរវេលាខ្លីបំផុត ចាប់ពី ៦ខែ ឡើងទៅ។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុននៅតែរក្សាគោលការណ៍ចាស់ដដែល គឺធ្វើកិច្ចសន្យាការងារមានថិរវេលាកំណត់២ខែម្តង និងកិច្ចសន្យាមានថិរវេលាមិនកំណត់។

២- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗពេលឈឺមានសំបុត្រពេទ្យត្រឹមត្រូវ។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ។

៣- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបន្ថែមលុយបាយថែមម៉ោងត្រឹមម៉ោង ៦ ល្ងាច ចំនួន ៤០០០ រៀល។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ជូនចំនួន ៣០០០ រៀល ដដែល។

៤- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូន។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ជូនទេ។

៥- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ច្បាប់ពិសេសសម្រាប់កម្មករនិយោជិតពេលមានធុរៈម្តងម្កាល។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនអនុញ្ញាតឱ្យប្រើច្បាប់ពិសេសបានលុះត្រាតែ កម្មករបានធ្វើការលើសពីពីរ (២)ខែ ឡើងទៅ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២០៨ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ (អាណត្តិទី១៥)។

THE ARBITRATION COUNCIL

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ឰូមេន លេខ ៨៣៦ ក.ប/អក/វក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៧ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ការិយាល័យវិវាទការងារទី៤ បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ១១១/០៧/១៧ ស.ស.យ.ក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីករណីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារចំនួន ១២ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក ការិយាល័យវិវាទការងារទី៤ នៃនាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ និងធ្វើការផ្សះផ្សាវិវាទចំនួន ១២ ចំណុច នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៧ ចំណុច និង ចំណុចមិនសះជាចំនួន ៥ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ទាំង ៥ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេ អឹម៣ (AM3) លេខ ៨៣៦ ក.ប/អក/វក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ៥ ចំណុចនេះ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ៥ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ ចំណុច គឺចំណុចវិវាទទី៥។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការសម្រេចលើចំណុចវិវាទដែលនៅសល់ចំនួន ៤ ចំណុចតែប៉ុណ្ណោះ គឺចំណុចវិវាទទី១, ទី២, ទី៣, និងទី៤។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់នាយកក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ផ្ទេរសិទ្ធិជូន លោក យន លីយ៉ុង ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ។

៣- លិខិត លេខ ០៤៨៥ ពណ.ចបព ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ របស់ក្រសួងពាណិជ្ជកម្ម បញ្ជាក់ថា ក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ជាក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ។

៤- លក្ខន្តិកៈក្រុមហ៊ុន អេ អិម ៣ (ខេមបូឌា) ហ្គាមេន បានតំកល់ទុកលេខ ០១២៤/២០១២ ពណ.ចបព ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

៥- លិខិតចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន អេ អិម ៣ (ខេមបូឌា) ហ្គាមេន គោរពជូន លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ ស្ដីពីសំណើសុំចុះទិដ្ឋាការលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អេ អិម ៣ (ខេមបូឌា) ហ្គាមេន បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវ លេខ ០៥៤ ករ/អក/អធក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ដោយប្រធាននាយកដ្ឋាន អធិការកិច្ចការងារ ។

៧- គំរូកិច្ចសន្យាសាកល្បងការងារ ។

៨- បទបញ្ជាផ្ទៃក្នុងរោងចក្រអេអឹម៣ ។

៩- គំរូកិច្ចសន្យាការងារមានថិរវេលាកំណត់រយៈពេល ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ១៣៦/០៩/១៧ ស.ស.យ.ខ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់សហព័ន្ធសហជីពយុវជនខ្មែរ (ស.ស.យ.ខ) គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពី សូមបញ្ជូនលោក ម៉ៃ វឌ្ឍនា អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ជាមន្ត្រីកិច្ចការច្បាប់ និងតំណាង

ដោះស្រាយវិវាទរបស់សហព័ន្ធសហជីពយុវជនខ្មែរ ចូលរួមសវនាការសម្រុះសម្រួលនូវវិវាទការងារ របស់កម្មករនិយោជិតជាមួយក្រុមហ៊ុន អេ អឹម ៣ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

២- លិខិតចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់គណកម្មការសហជីពយុវជនខ្មែរក្រុមហ៊ុន អេ អឹម ៣ គោរពជូន លោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរស្តីពីសំណើសុំពឹងពាក់ និងជួយអម និងជួយសម្រុះសម្រួលដោះស្រាយជាមួយក្រុមហ៊ុន-ក្រសួងការងារ-ក្រុមប្រឹក្សាអាជ្ញាកណ្តាល-តុលាការ-អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់ថ្នាក់ ដែលពាក់ព័ន្ធនូវការស្នើសុំលក្ខខណ្ឌការងារ របស់យើងខ្ញុំទាំងអស់គ្នា ដែលមានភ្ជាប់មកជាមួយ ។

៣- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ របស់កម្មករ-កម្មការិនីនៅក្រុមហ៊ុន អេ អឹម ៣ ផ្ទេរសិទ្ធិជូនថ្នាក់ដឹកនាំសហជីពយុវជនខ្មែរទាំង៣រូប មានលោក ប៊ូ ខេមរា លោក ផុន ហុងលី និង លោក វឿន សារ៉ាត់ ។

៤- លិខិតចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៧ របស់សហជីពយុវជនខ្មែរ ក្រុមហ៊ុន AM3 គោរពជូន លោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីសំណើសុំចូលជាសមាជិកសហព័ន្ធសហជីពយុវជនខ្មែរ ។

៥- លិខិតលេខ ១១១/០៧/១៧ ស.ស.យ.ខ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើសុំលោកប្រធានមេត្តាជួយដោះស្រាយនូវករណីវិវាទការងារក្នុងក្រុមហ៊ុន អេ អឹម៣ ។

៦- លិខិតលេខ ៩៥/០៦/១៧ ស.ស.យ.ខ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន លោកនាយកក្រុមហ៊ុន អេ អឹម ៣ ស្តីពីសំណើសុំជួបពិភាក្សា និងសម្រុះសម្រួលនូវករណីវិវាទការងាររបស់កម្មករនិយោជិត ។

៧- លិខិតពឹងពាក់ និងជួយអម របស់កម្មករ-កម្មការិនីនៃក្រុមហ៊ុន អេ អឹម ៣ គោរពជូន លោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីសំណើសុំពឹងពាក់ និងជួយអម និងជួយសម្រុះសម្រួលដោះស្រាយជាមួយក្រុមហ៊ុន-ក្រសួងការងារ-ក្រុមប្រឹក្សាអាជ្ញាកណ្តាល-តុលាការ-អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់ថ្នាក់ ដែលពាក់ព័ន្ធនូវការស្នើសុំលក្ខខណ្ឌការងាររបស់យើងខ្ញុំទាំងអស់គ្នា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ។

៩- លិខិតលេខ ០៧៧/១៧ ក.ប/វ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពយុវជនខ្មែររោងចក្រ អេ អឹម ៣ ជាអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត បានចុះបញ្ជិកានៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលស្របតាមច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ។

THE ARBITRATION COUNCIL

១០- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែររោងចក្រ អេ អីម ៣ លេខ ១១៣ ក.ប/វ.ប.វ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។

១១- បង្កាន់ដៃបង់ប្រាក់ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧។

១២- លិខិតសុំអនុញ្ញាតច្បាប់ អត្តលេខQC១០៩។

១៣- លិខិតបញ្ជាក់ របស់មន្ទីរពេទ្យខេត្តតាកែវ ផ្នែករោគស្ត្រី លេខ ១៥០៣/១៧ មពខ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ បញ្ជាក់ថា ឈ្មោះ ពិល សំណាង មានរោគវិនិច្ឆ័យត្រូវវះកាត់កូនក្រៅស្បូន។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន លេខ ៨៣៦ ក.ប/អក/វក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេ អិម ៣ ខេមបូឌា ហ្គាមេន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេ អិម ៣ (ខេមបូឌា) ហ្គាមេន លេខ ០១០/១៧/កប/អក/វក/លបវ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ២៣៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៣៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០១៧។

អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា៖

- ក្រុមហ៊ុន អេ អិម៣ (ខេមបូឌា) ហ្គាមេន តទៅនេះហៅថា "ក្រុមហ៊ុន អេ អិម៣" គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ និងបានទទួលលិខិតចុះបញ្ជីពាណិជ្ជកម្មក្រោម លេខ Co ០១០៩ E/២០១២ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២។ ភាគីនិយោជកអះអាងថា ក្រុមហ៊ុននេះមានចំនួនកម្មករនិយោជិតសរុបប្រមាណជិត ៣០០ នាក់។

- សហជីពយុវជនខ្មែររោងចក្រ អេ អឹម៣ ទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាសហជីព លេខ ១១២១៧០០៦៥ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ និងលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពខាងលើ តាមរយៈលិខិតលេខ ០៧៧/១៧ ក.ប/វក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយក្នុងនោះរួមមាន កម្មករនិយោជិតចំនួន ០៣ នាក់គឺ ១. លោក ប៊ូ ខេមរា ជាប្រធាន ២. លោក ផុន ហុងលី ជាអនុប្រធាន និង ៣. លោក រឿន សារ៉ាត់ ជាលេខាធិការ ។
- នាយកដ្ឋានវិវាទការងារបានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០១០/១៧/កប/អក/វក/លបវ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានឈ្មោះ ១. លោក ប៊ូ ខេមរា ២. លោក ផុន ហុងលី និង ៣. លោក រឿន សារ៉ាត់ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានឈ្មោះ អេ អឹម ៣ ដើម្បីដោះស្រាយវិវាទការងាររួមនៃសំណុំរឿង (គ្មានលេខ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ។
- នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល កម្មករនិយោជិតដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងកម្មករនិយោជិតខាងលើចំនួន ០២ នាក់ មានវត្តមាន គឺ ១. ប៊ូ ខេមរា និង ២. ផុន ហុងលី ។
- ភាគីទាំងពីរលើកឡើងថា នៅក្នុងក្រុមហ៊ុនមានសហជីពចំនួន ០២ ប៉ុន្តែមិនមានសហជីពដែលមានភាពជាតំណាងបំផុតនោះទេ ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកធ្វើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាខ្លីបំផុត ចាប់ពី ៦ខែ ឡើងទៅ**

- ភាគីទាំងពីរទទួលស្គាល់ថា ជាការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន គឺនិយោជកចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ២ខែ ម្តង ជាមួយកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុនដែលចូលធ្វើការចាប់ពីឆ្នាំ២០១៦ មក ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាយ៉ាងខ្លី ចំនួន ៦ ខែម្តង ជាមួយកម្មករនិយោជិត ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ២ខែ ធ្វើឱ្យមិនមានសុវត្ថិភាពការងារចំពោះកម្មករនិយោជិតទេ ។
  - ការចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ២ខែ គឺមិនអនុលោមទៅតាមច្បាប់ ។
  - ការចុះកិច្ចសន្យាការងារខ្លីៗនាំឱ្យប៉ះពាល់ដល់សិទ្ធិការងារ និងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ដូចជាប្រាក់រង្វាន់អតីតភាពការងារ ប្រាក់លំហែមាតុភាព និងការឈប់សម្រាកប្រចាំឆ្នាំ

- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនមានលទ្ធភាពក្នុងការអនុវត្តតាមការទាមទាររបស់កម្មករនិយោជិតទេ ដោយមូលហេតុថា ៖
    - ក្រុមហ៊ុននេះ គឺជាក្រុមហ៊ុនតូច ដែលទទួលដេរបន្តពីក្រុមហ៊ុនផ្សេងទៀត ហេតុនេះ មិនសូវមានការងារឱ្យកម្មករនិយោជិតធ្វើ ។
    - ការចុះកិច្ចសន្យាការងារដែលមានថិរវេលាកំណត់រយៈពេលវែងជាមួយកម្មករនិយោជិត ធ្វើឱ្យនិយោជកពិបាកគ្រប់គ្រងកម្មករនិយោជិត ដោយពួកគាត់មិនខិតខំបំពេញការងារ ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ពេលកម្មករនិយោជិតឈប់ឈឺដោយមានសំបុត្រពេទ្យត្រឹមត្រូវ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត ពិល សំណាង សម្រាប់អំឡុងពេលដែលគាត់ឈប់សម្រាកឈឺចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមានសំបុត្របញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - កម្មករនិយោជិត ពិល សំណាង បានឈប់សម្រាកដោយជំងឺ (វះកាត់កូនក្រៅស្បូន) ចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ។ ក្នុងនោះ កម្មករនិយោជិត ពិល សំណាង បានឈប់សម្រាករយៈពេលចំនួន ៧ថ្ងៃ នៅមន្ទីរពេទ្យ និងរយៈពេលចំនួន ១៥ថ្ងៃ នៅផ្ទះ ។
    - និយោជកយល់ព្រមផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗសម្រាប់រយៈពេល ៧ថ្ងៃ ដែលកម្មករនិយោជិតសម្រាកនៅមន្ទីរពេទ្យ ប៉ុន្តែ និយោជកមិនផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗឱ្យកម្មករនិយោជិតសម្រាប់រយៈពេល ១៥ ថ្ងៃ ដែលគាត់សម្រាកនៅផ្ទះនោះទេ ។
    - កម្មករនិយោជិតមិនព្រមទទួលយកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗសម្រាប់រយៈពេល ៧ថ្ងៃ នោះឡើយ ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន កម្មករនិយោជិតត្រូវទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗពេញ សម្រាប់រយៈពេលដែលកម្មករនិយោជិតឈប់សម្រាកឈឺ ។
- ភាគីនិយោជកបានបញ្ជាក់ជំហរថា មិនអាចផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត ពិល សំណាង សម្រាប់រយៈពេលដែលកម្មករនិយោជិតសម្រាកនៅផ្ទះបានទេ ពីព្រោះនិយោជកមិនមានលទ្ធភាព ។
- ភាគីកម្មករនិយោជិតបានលើកឡើងបន្ថែមថា ការឈប់សម្រាកបន្ថែមរយៈពេលចំនួន ១៥ថ្ងៃនោះ ធ្វើឡើងតាមដំបូន្មានរបស់គ្រូពេទ្យ ដោយផ្អែកលើស្ថានភាពជំងឺរបស់កម្មករនិយោជិត ។ ហេតុនេះ ទោះបីកម្មករនិយោជិតឈប់សម្រាកនៅផ្ទះក៏ដោយ ក៏និយោជកត្រូវផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗពេញដែរ ។

- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អេ អិមពា ដែលបានទទួលទិដ្ឋាការនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ត្រង់ប្រការ ៤ ពាក់ព័ន្ធនឹងពេលម៉ោងធ្វើការ និងការឈប់សម្រាក ចំណុច "*ការឈប់សម្រាកដោយជម្ងឺ*" ចែងថា ៖ "*...ចំពោះអ្នកមានជម្ងឺ ដែលមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពេញក្នុងរយៈពេល ១ ខែដំបូង ។...*" ។
- ភាគីកម្មករនិយោជិតបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវលិខិតបញ្ជាក់ពីមន្ទីរពេទ្យខេត្ត តាកែវ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមានត្រា និងហត្ថលេខា របស់ប្រធានមន្ទីរពេទ្យខេត្តតាកែវ ព្រមទាំងហត្ថលេខា និងឈ្មោះ របស់គ្រូពេទ្យព្យាបាលផង ដោយបានបញ្ជាក់ថា ៖

  "*ឈ្មោះ ពិល សំណាង...*

  *...*

  *រោគវិនិច្ឆ័យ វះកាត់កូនក្រពេញ*

  *ដំបូន្មានគ្រូពេទ្យ : ត្រូវសម្រាកព្យាបាលកន្លះខែ ...*" ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកទទួលស្គាល់ថា លិខិតបញ្ជាក់របស់គ្រូពេទ្យដែលភាគីកម្មករនិយោជិតផ្តល់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាលិខិតត្រឹមត្រូវ ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងត្រឹមម៉ោង ៦ ល្ងាច ឱ្យបានចំនួន ៤០០០ រៀល**

- ភាគីកម្មករនិយោជកបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល ក្នុងមួយថ្ងៃ នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោង ពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទី ល្ងាច ។
- ភាគីទាំងពីរទទួលស្គាល់ថា ការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន គឺនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៣០០០ រៀល ក្នុងមួយថ្ងៃ នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោង ពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទី ល្ងាច ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ៣០០០ រៀល កម្មករនិយោជិតមិនអាចទិញម្ហូបអាហារហូបគ្រប់គ្រាន់ទេ ។
  - ក្រុមហ៊ុនដទៃទៀតដែលមានទីតាំងនៅជិតក្រុមហ៊ុន អេ អិមពា ផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ៤០០០ រៀល ជូនកម្មករនិយោជិត ។ ហេតុនេះ កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន អេ អិមពា ចង់ទទួលបានប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ៤០០០ រៀល ដូចការផ្តល់ជូននៅក្នុងក្រុមហ៊ុនដទៃទៀតដែរ ។

THE ARBITRATION COUNCIL

- ភាគីនិយោជកបានឆ្លើយតបថា និយោជកមិនមានលទ្ធភាពផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោ-ជិតទេ ពីព្រោះ ការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៣០០០ រៀល គឺមានលក្ខណៈល្អប្រសើរជាងច្បាប់ហើយ ។

**ចំណុចវិវាទទី ៤ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូន***

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅកូន ឬផ្តល់ប្រាក់ថ្លៃទឹកដោះគោប្រចាំខែ ជូនកម្មករនិយោជិតជាស្ត្រីដែលមានកូនតូច ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - នៅក្នុងក្រុមហ៊ុនមានកម្មករនិយោជិតជាស្ត្រីច្រើនជាង ១០០ នាក់ ។
    - នៅក្នុងក្រុមហ៊ុនមិនទាន់មានទារកដ្ឋាន និងបន្ទប់បំបៅដោះកូននៅឡើយទេ ។
    - និយោជកមិនមានផ្តល់ប្រាក់ថ្លៃទឹកដោះគោប្រចាំខែ ឬផ្តល់ប្រាក់ថ្លៃសេវាមើលថែទារកជូនកម្មករនិយោជិតទេ ។
- ភាគីនិយោជកបានឆ្លើយតបថា និយោជកមិនមានលទ្ធភាពផ្តល់ជូនតាមការទាមទារនេះទេ ។
- ភាគីនិយោជកបានបញ្ជាក់បន្ថែមទៀតថា ៖
    - នៅក្នុងក្រុមហ៊ុនមានកម្មករនិយោជិតជាស្ត្រីដែលមានកូនតូចតែ ២ ទៅ ៣ នាក់ តែប៉ុណ្ណោះ ។
    - តាមរយៈការចូលរួមសិក្ខាសាលាកន្លងមក រដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារបានមានប្រសាសន៍ថា ក្រុមហ៊ុនទាំងអស់នៅក្នុងប្រទេសកម្ពុជាមានតែក្រុមហ៊ុនប្រមាណ ២៨ ភាគរយ តែប៉ុណ្ណោះ ដែលបានរៀបចំសង់ទារកដ្ឋានតាមច្បាប់ស្តីពីការងារ ។ និយោជកយល់ឃើញថា ក្រុមហ៊ុន អេ អិម៣ ជាក្រុមហ៊ុនតូចមួយ និងមានកម្មករនិយោជិតតិច ហើយរាជរដ្ឋាភិបាលមិនទាន់មានវិធានការចាប់បង្ខំឱ្យក្រុមហ៊ុនទាំងឡាយសង់ទារកដ្ឋាននៅឡើយទេ ។ ហេតុនេះ និយោជកនឹងសាងសង់ទារកដ្ឋាននៅពេលនិយោជកមានលទ្ធភាព ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុនពិចារណាចំណុចទាមទារខាងក្រោមនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយជាមុនសិន អំពីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន ។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ ។"*

យោងតាមកថាខណ្ឌទី១ នៃមាត្រា៥៤ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាអនុសញ្ញារួម និង ដោះស្រាយវិវាទការងាររួម ។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយក

ARBITRATION COUNCIL

វិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ ។ *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី, លេខ ១៨៣/១៦-យីដា មេនូហ្វេកឌឺរី ខូអិលធីឌី, ១៨៤/១៦-ឃ្វីនធ៍ មេជើរ អ៊ីនដាសស្ទ្រៀល ខូអិលធីឌី, លេខ ១៨៨/១៦-ហ្វ្រីនសាំមីត (ខេមបូឌា) លីមីធីត និងលេខ ២២៧/១៦-អេវើរី ដេកស្ដាយ ហ្វាមេន (ខេមបូឌា) ខូអិលធីឌី)*

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ក្រុមហ៊ុន អេ អិមា មិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតនៅឡើយទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងលេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង បានបកស្រាយថា ៖ *"...អវត្តមាននៃសហជីពដែលមានភាពជាតំណាងបំផុតនេះ អាចបណ្ដាលឱ្យមានភាពរាំងស្ទះដល់សិទ្ធិតំណាងសម្រាប់កម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម និងអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមូលដ្ឋានក្នុងការប្ដឹងតវ៉ា ឬទាមទារសំណង ដែលផ្ដល់ឱ្យកម្មករនិយោជិតដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។*

*...ក្នុងករណីដែលសហគ្រាស ឬគ្រឹះស្ថានមួយមិនទាន់មានអត្ថិភាពនៃសហជីពដែលមានភាពជាតំណាងបំផុត កម្មករនិយោជិតដែលជាប់ពាក់ព័ន្ធក្នុងវិវាទមានសិទ្ធិតំណាងដោយផ្ទាល់ខ្លួន ឬមានសិទ្ធិក្នុងការពឹងពាក់ ឬផ្ទេរសិទ្ធិជូនសហជីពមូលដ្ឋាន ឬបុគ្គលផ្សេងទៀត ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប្រសិនបើពួកគាត់យល់ថា សិទ្ធិរបស់ពួកគាត់ត្រូវបានបំពានដោយនិយោជក ។"* ។ *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី, លេខ ១៨៣/១៦-យីដា មេនូហ្វេកឌឺរី ខូអិលធីឌី, ១៨៤/១៦-ឃ្វីនធ៍ មេជើរ អ៊ីនដាសស្ទ្រៀល ខូអិលធីឌី, លេខ ១៨៨/១៦-ហ្វ្រីន សាំមីត (ខេមបូឌា) លីមីធីត, លេខ ១៩៧/១៦-ស៊ិន ជីធាន (ខេមបូឌា) និងលេខ ២១០/១៦-ហ្វ្រេត អននើរ ដេកស្ដាយ ហ្វេកធើរី លីមីធីត)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។

ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបញ្ជើងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម ។"* ។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុង[illegible] កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

THE ARBITRATION COUNCIL

ខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត ។ (*សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល លេខ ២២៣/១៦-យូនីកតា ថេកណេឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ផបរើលជ័ ហ្គាមិន (ខេមបូឌា) អិលធីឌី និង លេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច*)

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ កំយល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០១០/១៧/កប/អក/វក/លបវ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានឈ្មោះ ១. លោក ប៊ូ ខេមរា ២. លោក ផុន ហុងលី និង ៣. លោក រឿន សារ៉ាត់ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានឈ្មោះ អេ អិមពា ដើម្បីដោះស្រាយវិវាទការងាររួមនៃសំណុំរឿងនេះ ។

នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល កម្មករនិយោជិតដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាង កម្មករនិយោជិត ២ នាក់ មានវត្តមាន គឺកម្មករនិយោជិត ១. ប៊ូ ខេមរា និង ២. ផុន ហុងលី ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតទាំង ២ នាក់ មានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន អេ អិមពា ក្នុងការដោះស្រាយវិវាទការងាររួមនៅក្នុងក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណាចំណុចវិវាទក្នុងសំណុំរឿងនេះសម្រាប់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន អេ អិមពា ដែលជាដើមបណ្ដឹង ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកចុះកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាយ៉ាងខ្លីចំនួន ៦ ខែម្ដង ជាមួយកម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាយ៉ាងខ្លីចំនួន ៦ ខែម្ដង ជាមួយកម្មករនិយោជិតដែរ ឬទេ?

កថាខណ្ឌទី១នៃមាត្រា ៦៥ ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "*កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានទំនាក់ទំនងផ្នែកការងាររវាងកម្មករនិយោជិត និងនិយោជក ។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា ។*" ។

កថាខណ្ឌទី១ នៃមាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ កំណត់និយមន័យនៃកិច្ចសន្យាការងារ ៖ "*កិច្ចសន្យាការងារ ត្រូវបានបង្កើតឡើងដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថាផ្ដល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ ។*"

ខ្លឹមសារនៃមាត្រា ៦៥ នៃច្បាប់ស្តីពីការងារ និងមាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណីខាងលើបានកំណត់និយមន័យនៃកិច្ចសន្យាការងារ ដែលបំពេញន័យឱ្យគ្នាទៅវិញទៅមក។ ជាក់ស្តែង មាត្រា ៦៥ នៃច្បាប់ស្តីពីការងារបានកំណត់ថា កិច្ចសន្យាការងារស្ថិតក្រោមវិធានទូទៅនៃការបង្កើតកិច្ចសន្យាផងដែរដែលបច្ចុប្បន្ននេះ ស្ថិតនៅក្រោមវិធាននៃក្រមរដ្ឋប្បវេណី។

ក្រៅពីនេះ មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីដដែល ចែងថា៖ "*កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់ មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ និងរំលាយនូវកាតព្វកិច្ច។*" ។

មាត្រានេះ មានន័យថា កិច្ចសន្យាកើតឡើងដោយសារឆន្ទៈរបស់ភាគី ហើយភាគីអាចបង្ហាញឆន្ទៈព្រមព្រៀងគ្នា ក្នុងការកែប្រែ និងរំលាយនូវកាតព្វកិច្ចបានផងដែរ។

បន្ថែមពីនេះ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី កំណត់ថា៖ "*កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្ទីការត្រូវគ្នា។*" ។

មាត្រានេះ មានន័យថា កិច្ចសន្យាអាចធ្វើទៅបាន លុះត្រាណាតែមានការព្រមព្រៀងគ្នា រវាងអ្នកធ្វើសំណើ និងអ្នកធ្វើស្ទីការ។

កថាខណ្ឌទី១ និងទី៣ នៃមាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណីខាងលើ ចែងថា៖ "*សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ*" ។

*ស្ទីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។*" ។

ផ្អែកតាមមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គ្មានភាគីណាមួយនៃកិច្ចសន្យាអាចបង្ខំភាគីមួយផ្សេងទៀត ឱ្យទទួលយកទម្រង់ ឬប្រភេទ និងខ្លឹមសារនៃកិច្ចសន្យា ដែលភាគីម្ខាងទៀតមិនឯកភាពបានឡើយ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានទំនាក់ទំនងផ្នែកការងាររវាងកម្មករនិយោជិត និងនិយោជក ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា (សំណើ និងស្ទីការត្រូវគ្នា) ឱ្យតែលក្ខខណ្ឌនោះស្របតាមច្បាប់ស្តីពីការងារ។ កិច្ចសន្យានេះត្រូវស្ថិតក្រោមវិធានអាជ្ញាគតិ។ គ្មានភាគីណាមួយនៃកិច្ចសន្យាអាចបង្ខំភាគីមួយទៀតឱ្យចុះកិច្ចសន្យា ឬទទួលយកលក្ខខណ្ឌ ដែលភាគីមួយទៀតមិនអាចទទួលយកបានឡើយ (សំណើ និងស្ទីការ មិនត្រូវគ្នា)។ កិច្ចសន្យាធ្វើឡើងដោយបង្ខំ បើកសិទ្ធិឱ្យភាគីម្ខាងទៀតលុបចោលកិច្ចសន្យានោះបាន។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៥៦/០៦-បូរិក ហេតុផលនៃចំណុចវិវាទទី១, លេខ ៩៦/១៣-អេហ្វ ដាប់ប៊ែល យូ ខេ ខេ, លេខ ២០៤/១៣-បូវេយី ហ្គាមេន ហេតុផលនៃចំណុចវិវាទទី១០, លេខ ០១៦/១៤-សាន់ វែល ស៊ូ ហេតុផលនៃចំណុចវិវាទទី០៥, លេខ ១៩១/១៥-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច ហេតុផលនៃចំណុចវិវាទទី០៩, លេខ ១[illegible]/១៦-ស្រាបៀរកម្ពុជា ខេមប្រ៊ូវ ហេតុផលនៃចំណុចវិវាទទី២ និងលេខ ២១៩/១៦-យូ.ឌី.អេស ហ្គាមេន ហេតុផលនៃចំណុចវិវាទទី៤*)

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។

តាមរយៈអង្គហេតុ ជាការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន និយោជកចុះកិច្ចសន្យាការងារមានកំណត់ថិរវេលាចំនួន ២ ខែម្តង ជាមួយកម្មករនិយោជិត ។ យ៉ាងណាមិញ ភាគីកម្មករនិយោជិតបានទាមទារឱ្យនិយោជកចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាយ៉ាងខ្លីចំនួន ៦ ខែម្តង ។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ជំហរមិនអនុវត្តតាមការទាមទាររបស់កម្មករនិយោជិតទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់ភាគីកម្មករនិយោជិត មិនផ្ទុយពីស្មារតីនៃច្បាប់ទេ ព្រោះវាជាសិទ្ធិរបស់ភាគីកម្មករនិយោជិត នៅពេលធ្វើសំណើដើម្បីបង្កើតកិច្ចសន្យាការងារ ។ ចំណែកឯការបដិសេធរបស់ភាគីនិយោជក ក៏មិនខុសច្បាប់ដែរ ព្រោះថា វាជាសិទ្ធិរបស់និយោជកនៅពេលធ្វើស្ទីការចំពោះសំណើរបស់កម្មករនិយោជិត ។ ជាគោលការណ៍ គ្មានភាគីណាមួយអាចបង្ខំឱ្យភាគីមួយទៀតទទួលយកលក្ខខណ្ឌ ដែលខ្លួនមិនព្រមទទួលយកនោះទេ ។

ក្នុងករណីនេះ កម្មករនិយោជិតមិនអាចបង្ខំឱ្យនិយោជកចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ៦ខែ ជាមួយកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន តាមសំណើរបស់ខ្លួនបានទេ ចំណែកឯនិយោជកក៏មិនអាចបង្ខំឱ្យកម្មករនិយោជិតចុះកិច្ចសន្យាការងារមានកំណត់ថិរវេលា ចំនួន ២ខែ ជាមួយខ្លួនបានដែរ ប្រសិនបើកម្មករនិយោជិតមិនយល់ព្រម ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាយ៉ាងខ្លីចំនួន ៦ ខែម្តង ជាមួយកម្មករនិយោជិត ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ពិល សំណាង សម្រាប់អំឡុងពេលដែលគាត់ឈប់សម្រាកឈឺចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមានសំបុត្របញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ពិល សំណាង សម្រាប់អំឡុងពេលដែលគាត់ឈប់សម្រាកឈឺចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមានសំបុត្របញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យដែរ ឬទេ?

ទាក់ទងនឹងចំណុចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ប្រការ ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អេ អិម៣ ដែលបានទទួលទិដ្ឋាការនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ត្រង់ចំណុច "*ការឈប់សម្រាកដោយជម្ងឺ*" ចែងថា ៖ "*...ចំពោះអ្នកមានជម្ងឺ ដែលមានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពេញក្នុងរយៈពេល ១ ខែដំបូង ។...*" ។

តាមរយៈអង្គហេតុខាងលើ ភាគីទាំងពីរបានទទួលស្គាល់ថាកម្មករនិយោជិត ពិល សំណាង បានឈប់សម្រាកដោយជំងឺ ចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមាន

នោះ គាត់សម្រាកនៅមន្ទីរពេទ្យរយៈពេល ៧ថ្ងៃ និងសម្រាកនៅផ្ទះរយៈពេល ១៥ថ្ងៃ។ និយោជកព្រមផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗសម្រាប់តែរយៈពេលដែលកម្មករនិយោជិត ពិល សំណាង សម្រាកនៅមន្ទីរពេទ្យ ចំនួន ៧ថ្ងៃ ប៉ុណ្ណោះ ប៉ុន្តែមិនផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗសម្រាប់រយៈពេល ១៥ថ្ងៃ ដែលគាត់សម្រាកនៅផ្ទះនោះឡើយ ។

ភាគីកម្មករនិយោជិតបានលើកឡើងថា ការឈប់សម្រាកនៅផ្ទះរបស់កម្មករនិយោជិត ពិល សំណាង រយៈពេល ១៥ថ្ងៃនេះ ធ្វើឡើងស្របតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ ដោយយោងលើស្ថានភាពជំងឺរបស់កម្មករនិយោជិត ដូចដែលមានបញ្ជាក់នៅក្នុងលិខិតបញ្ជាក់ ដែលភាគីកម្មករនិយោជិតបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ហេតុនេះ បើទោះបីជាកម្មករនិយោជិត ពិល សំណាង មិនបានសម្រាកនៅមន្ទីរពេទ្យក៏ដោយ ក៏និយោជកត្រូវផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗពេញ ឱ្យគាត់សម្រាប់រយៈពេល ១៥ថ្ងៃ ដែលគាត់ឈប់សម្រាកឈឺផងដែរ ។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ជំហរថា មិនមានលទ្ធភាពផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនគាត់សម្រាប់រយៈពេលឈប់សម្រាកឈឺនៅផ្ទះនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ភាគីនិយោជកទទួលស្គាល់ថា លិខិតបញ្ជាក់របស់គ្រូពេទ្យដែលភាគីកម្មករនិយោជិតផ្តល់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាលិខិតត្រឹមត្រូវ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការឈប់សម្រាកដោយជំងឺបន្ថែមនៅផ្ទះរបស់កម្មករនិយោជិត ពិល សំណាង រយៈពេល ១៥ថ្ងៃ ធ្វើឡើងតាមដំបូន្មានរបស់គ្រូពេទ្យ ។ ម្យ៉ាងទៀត នៅក្នុងបទបញ្ជាផ្ទៃក្នុង មិនមានការកំណត់ជាក់លាក់ណាមួយរបស់ក្រុមហ៊ុន ដែលបញ្ជាក់ថា ការឈប់សម្រាកដោយជំងឺ ចាំបាច់ត្រូវតែជាការឈប់សម្រាកនៅមន្ទីរពេទ្យនោះឡើយ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការលើកឡើងរបស់ភាគីនិយោជក គឺមិនត្រឹមត្រូវឡើយ ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ទាក់ទងនឹងការផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលឈប់សម្រាកដោយជំងឺ។ ដូចនេះ និយោជកត្រូវផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ចំនួន ២២ថ្ងៃ ដល់កម្មករនិយោជិត ពិល សំណាង សម្រាប់អំឡុងពេលដែលគាត់ឈប់សម្រាកឈឺ ដោយមានសំបុត្របញ្ជាក់ពីគ្រូពេទ្យ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ។

ប្រការ ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណងខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ...ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ ដែលត្រូវបង់... ។"* ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ពិល សំណាង សម្រាប់អំឡុងពេលដែលគាត់ឈប់សម្រាកឈឺចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមានសំបុត្របញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ។

ARBITRATION COUNCIL

ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល ក្នុងមួយថ្ងៃ នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោងពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទីល្ងាច

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោងពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទី ល្ងាច ដែរ ឬទេ?

តាមរយៈអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា ការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន គឺនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៣០០០រៀល នៅពេលកម្មករនិយោជិតធ្វើការបន្ថែម ពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទី ល្ងាច ។

ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា “*កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ*” ។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ស្របតាមការកំណត់នៅក្នុងសេចក្តីជូនដំណឹងលេខ ០៤១/១១ ខាងលើរួចហើយ ។

តាមរយៈការទាមទារខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិណាមួយ នៃច្បាប់ស្តីពីការងារ អនុសញ្ញារួម បទបញ្ជាផ្ទៃក្នុង កិច្ចសន្យាការងារ កិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ឬ ការអនុវត្តកន្លងមកណាមួយ ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ក្នុងមួយម៉ោងចំនួន ៤០០០ រៀល នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោង ពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទី ល្ងាច នោះទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់ភាគីកម្មករនិយោជិត គឺជាការទាមទារនូវអត្ថប្រយោជន៍ដែលលើសពីការកំណត់នៅក្នុងច្បាប់ស្តីពីការងារ ។ ហេតុនេះ ការទាមទារនេះជាវិវាទអំពីផលប្រយោជន៍ ។

កថាខណ្ឌទី២ នៃមាត្រា៩៦ នៃច្បាប់ស្តីពីការងារ ចែងថា “*២-អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងមាត្រា៩៦ កថាខណ្ឌទី១ អនុសញ្ញារួមត្រូវធ្វើឡើងដោយព្រមព្រៀងគ្នារវាង ៖*

*ក. មួយចំណែក គឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយ ឬអង្គការច្រើនតំណាងឱ្យនិយោជក ។*

*ខ. មួយចំណែកទៀត គឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត ។...*”

លើសពីនេះ កថាខណ្ឌទី១ នៃប្រការ ៩ នៃប្រកាសលេខ ៣០៥ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួម

THE ARBITRATION COUNCIL

នៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចែងថា ៖ "សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចាអំពីអនុសញ្ញារួម ដែលអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ។ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ចត្រូវតែធ្វើការចរចាជាមួយសហជីព ។"

មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ "ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ ។

សហជីពមួយនឹងទទួលបានភាពជាតំណាងបំផុត លុះត្រាតែសហជីពនោះបានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យដូចតទៅ ៖

...

គ- មានសមាជិកដែលមានបណ្ណសម្គាល់ និងបញ្ជីឈ្មោះសមាជិកត្រឹមត្រូវច្រើនជាងគេ ឬទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយ ដូចករណីខាងក្រោម ៖

- សហជីពដែលមានសមាជិកចាប់ពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពតែមួយ ឬ

- សហជីពណាដែលស្វែងរកបានការគាំទ្រពីសហជីពដទៃច្រើនជាងគេបំផុតដោយលើសពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីព លើសពី ១ (មួយ) ឬ

- ក្នុងករណីសហជីពណាមួយពុំអាចរកសមាជិកគាំទ្របានចាប់ពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុប ត្រូវរៀបចំការបោះឆ្នោតស្វែងរកការគាំទ្រឱ្យបានសំឡេងច្រើនជាងគេបំផុតលើសពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬ គ្រឹះស្ថាននោះ។... ។

ប្រសិនបើនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយមានសហជីពមូលដ្ឋានច្រើនផ្សេងៗគ្នា មិនអាចបំពេញគ្រប់លក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ហើយពុំអាចស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា ៧២ (ក្រុមប្រឹក្សាចរចា) នៃច្បាប់នេះ ។ " ។

មាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើដដែល ចែងថា ៖ "ក្រុមប្រឹក្សាចរចានៃសហជីព និងនិយោជក ដែលត្រូវបានបង្កើតឡើង មានសិទ្ធិពេញលេញក្នុងនាមកម្មករនិយោជិតទាំងអស់ ឬនិយោជកទាំងអស់នៅគ្រប់កម្រិត ថ្នាក់ចរចាក្នុងករណីដែលត្រូវមានការចរចាចុះអនុសញ្ញារួមរវាងនិយោជកមួយ និងសហជីពច្រើនដែលមានភាពជាតំណាងបំផុត ឬរវាងនិយោជកច្រើន និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត ។"

យោងតាមកថាខណ្ឌទី២ មាត្រា ៩៦ នៃច្បាប់ស្តីពីការងារ, មាត្រា ៥៤ និងមាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើភាពជាតំណាងបំផុតរបស់សហជីពដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីពនេះ ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងពាក់ព័ន្ធនឹងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

កថាខណ្ឌទី១ នៃប្រការ៤៣ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ ។"* ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃប្រការ៤៣ នៃប្រកាស ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់បាត់បង់សិទ្ធិក្នុងការចរចាអនុសញ្ញារួម និងសិទ្ធិក្នុងការធ្វើកូដកម្ម ដើម្បីទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស ឬសហជីពមូលដ្ឋានច្រើនផ្សេងគ្នា ដែលមានសិទ្ធិក្នុងការចរចាចុះអនុសញ្ញារួម ស្របតាមមាត្រា ៥៤ និងមាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើ ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលអាចនាំវិវាទអំពីផលប្រយោជន៍ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨១/០៤-អេវើប្រ៊្ពីន ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៨/០៤-ហ្រ្គេតយូនៀន ហេតុផលនៃចំណុចវិវាទទី៣, លេខ ០២/១១-ពូ យឿន ហេតុផលនៃចំណុចវិវាទទី២, លេខ ៦៦/១១-អ៊ិន ហាន ស៊ីង ហេតុផលនៃចំណុចវិវាទទី១, លេខ ១១៨/១៦-អ៊ី-ចេង (ខេមបូឌា) ខបភើរេសិន ហេតុផលនៃចំណុចវិវាទទី[illegible] និងលេខ ២០៣/១៦-អ៊ិនយ៉ុង វ៉ុនដាង អ៊ីកែវីល ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៤)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើនេះដែរ ។

នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតជាភាគីដើមបណ្តឹង មិនមែនជាសហជីពដែលមានភាពជាតំណាងបំផុត ឬជាសហជីពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីសហជីព ក្នុងការនាំវិវាទដែលទាក់ទងនឹងផលប្រយោជន៍មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើការពិចារណានោះឡើយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើមបណ្តឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការនាំវិវាទដែលទាក់ទងនឹងផលប្រយោជន៍មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើការពិចារណានោះឡើយ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោងពីម៉ោង ០៤ ៖០០ ដល់ ០៦៖០០ នាទី ល្ងាច។

**ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅកូន ឬផ្តល់ប្រាក់ថ្លៃទឹកដោះគោប្រចាំខែជូនកម្មករនិយោជិតជាស្ត្រីដែលមានកូនតូច**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចរៀបចំឱ្យមានទារកដ្ឋាន និងបន្ទប់បំបៅកូន ឬផ្តល់ប្រាក់ថ្លៃទឹកដោះគោប្រចាំខែជូនកម្មករនិយោជិតជាស្ត្រីដែលមានកូនតូចដែរ ឬទេ?

មាត្រា១៨៦ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"នាយកសហគ្រាសទាំងឡាយដែលប្រើស្ត្រីចាស់ក្តី ក្មេងក្តី ចំនួនយ៉ាងតិចមួយរយនាក់ត្រូវរៀបចំបន្ទប់សំរាប់បំបៅកូនមួយក្នុងគ្រឹះស្ថាន ឬនៅជិតនោះ ហើយនិងទារកដ្ឋានមួយផង។ ក្នុងករណីដែលសហគ្រាសពុំមានលទ្ធភាពរៀបចំទារកដ្ឋាន សំរាប់ទទួលកុមារអាយុលើសពីដប់ប្រាំបីខែផ្ទាល់បានទេ នារីជាកម្មករនិយោជិតអាចផ្ញើកូនរបស់ខ្លួននៅទារកដ្ឋានណាមួយ ដោយនិយោជកជាអ្នកចេញសោហ៊ុយថែរក្សាទារក នោះ"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបកស្រាយមាត្រា១៨៦ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ថា ៖ *"និយោជកត្រូវរៀបចំឱ្យមានបន្ទប់បំបៅកូន និងទារកដ្ឋានសម្រាប់កម្មការិនី ដែលមានកូនដែលត្រូវយកទៅផ្ញើ។ ក្នុងករណីដែលនិយោជកពុំអាចរៀបចំឱ្យមានទារកដ្ឋានបានទេ កម្មការិនីដែលមានកូនតូចចាប់ពីអាយុ ១៨ ខែឡើង ទៅអាចយកកូនទៅផ្ញើនៅទារកដ្ឋានណាមួយ (នៅខាងក្រៅ) ដែលនិយោជកជាអ្នកទទួលខុសត្រូវចេញសោហ៊ុយ នៃការថែទាំនេះ តាមវិក្កយបត្រជាក់ស្តែង"*។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៨១/០៩-វ៉ន វេច ហេតុផលនៃចំណុចវិវាទទី៣, លេខ ១៥០/១៤-ល្បៀនហួ (ខេមបូឌា) ហ្គាមិនខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៧, លេខ ០០៦ & ០១០/១៦-ខេម វើណា ហ្វេសិន ខូ អិលធីឌី ហេតុផលនៃចំណុចវិវាទទី៤, លេខ ០២២/១៦-អាត់តាឌីស (ខេមបូឌា) ហ្គាមេន ហេតុផលនៃចំណុចវិវាទទី៨)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងពីមុនៗខាងលើដែរ។

យោងតាមអង្គហេតុ កម្មករនិយោជិតជាស្ត្រីក្នុងក្រុមហ៊ុននេះ មានចំនួនសរុបលើសពី ១០០នាក់ ភាគីទាំងពីរទទួលស្គាល់ថា បច្ចុប្បន្ន និយោជកមិនទាន់បានរៀបចំទារកដ្ឋាន និងបន្ទប់បំបៅកូនទេ។

THE ARBITRATION COUNCIL

ហេតុនេះ យោងតាមការបកស្រាយមាត្រា ១៨៦ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចក្នុងការរិះរកនូវវិធានការសមស្រប ដើម្បីរៀបចំឱ្យមានបន្ទប់បំបៅកូន និងទារកដ្ឋានសម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រីដែលមានកូនត្រូវយកទៅផ្ញើ ឬក្នុងករណីដែលនិយោជកពុំអាចរៀបចំឱ្យមានទារកដ្ឋានបានទេ កម្មករនិយោជិតជាស្ត្រីដែលមានកូនតូចចាប់ពីអាយុ ១៨ ខែ ឡើងទៅ អាចយកកូននេះទៅផ្ញើនៅទារកដ្ឋានណាមួយនៅខាងក្រៅ ហើយនិយោជកជាអ្នកទទួលខុសត្រូវចេញសោហ៊ុយនៃការថែទាំនេះ តាមវិក្កយបត្រជាក់ស្តែង។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជករៀបចំទារកដ្ឋាន និងបន្ទប់បំបៅកូនសម្រាប់កម្មករនិយោជិតជាស្ត្រីយកកូនទៅផ្ញើ។ ក្នុងករណី ដែលនិយោជកពុំអាចរៀបចំឱ្យមានទារកដ្ឋាន សម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រី ដែលមានកូនអាយុចាប់ពី១៨ ខែឡើងទៅ យកកូនទៅផ្ញើ កម្មករនិយោជិតជាស្ត្រីនោះអាចយកកូនទៅផ្ញើនៅទារកដ្ឋានណាមួយនៅខាងក្រៅ ហើយនិយោជកជាអ្នកទទួលខុសត្រូវចេញសោហ៊ុយថែទាំក្មេងតាមវិក្កយបត្រជាក់ស្តែង។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាយ៉ាងខ្លីចំនួន ៦ ខែម្តង ជាមួយកម្មករនិយោជិត។

**ចំណុចវិវាទទី ២៖**

- បង្គាប់ឱ្យនិយោជកសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ពិល សំណាង សម្រាប់អំឡុងពេលដែលគាត់ឈប់សម្រាកឈឺចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ដោយមានសំបុត្របញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ។

**ចំណុចវិវាទទី ៣៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០ រៀល នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោងពីម៉ោង ០៤៖០០ ដល់ ០៦៖០០ នាទី ល្ងាច។

**ចំណុចវិវាទទី ៤៖**

- បង្គាប់ឱ្យនិយោជករៀបចំទារកដ្ឋាន និងបន្ទប់បំបៅកូន សម្រាប់កម្មករនិយោជិតជាស្ត្រីយកកូនទៅផ្ញើ។ ក្នុងករណីដែលនិយោជកពុំអាចរៀបចំឱ្យមានទារកដ្ឋាន សម្រាប់ឱ្យកម្មករនិយោជិតជាស្ត្រី ដែលមានកូនអាយុចាប់ពី១៨ ខែឡើងទៅ យកកូនទៅផ្ញើ កម្មករនិយោជិតជាស្ត្រីនោះ អាចយកកូនទៅផ្ញើនៅទារកដ្ឋានណាមួយនៅខាងក្រៅ ហើយនិយោជកជាអ្នកទទួលខុសត្រូវចេញសោហ៊ុយថែទាំតាមវិក្កយបត្រជាក់ស្តែង។

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL